The Goldman Environmental Prize

**ទំនាក់ទំនង :**
Natalie Silverstein
Goldman Environmental Prize
(415) 345-6330
natalie@goldmanprize.org

**ត្រូវបានដាក់កំហិតក្នុងការចេញផ្សាយរហូតដល់ថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០១០**

**នៅម៉ោង ១២:០១ ព្រឹក (ម៉ោងតំបន់ប៉ាស៊ីហ្វិក)/ ៧:០១ ព្រឹក (ម៉ោងសកល)**

## រង្វាន់ផ្នែកបរិស្ថានមនុស្សមាសចំនួន $150,000 ទៅឱ្យវីរបុរសផ្នែកបរិស្ថានចំនួនប្រាំមួយនាក់

*បណ្ដាអ្នកឈ្នះឆ្នាំ2010 មកពីប្រទេសស្វាស៊ីលែនដ៍ កម្ពុជា ប៉ូឡូញ គុយបា សហរដ្ឋអាមេរិក និងកូស្តារីកា*

**សាន់ហ្វ្រាន់ស៊ីស្កូ ថ្ងៃទី 19 ខែ មេសា ឆ្នាំ 2010** – មូលនិធិផ្នែកបរិស្ថានមនុស្សមាស (Goldman Environmental Foundation) បានប្រកាសប្រាប់ពីអ្នកទទួលបានរង្វាន់ផ្នែកបរិស្ថានមនុស្សមាសឆ្នាំ 2010 ទាំងប្រាំមួយនាក់ ដែលជាក្រុមអ្នកដឹកនាំលេចធ្លោមិនមានភាពភ័យខ្លាច ទទួលយកនូវបញ្ហាបរិស្ថានដ៏មានសម្ពាធបំផុតរបស់ពិភពលោកមួយចំនួន ដែលប៉ះពាល់មិនត្រឹមតែសហគមន៍ក្នុងមូលដ្ឋានប៉ុណ្ណោះទេ តែថែមទាំងពិភពលោកទាំងមូលផងដែរ ។

បណ្ដាអ្នកទទួលបានរង្វាន់ ដោះស្រាយបញ្ហាបានជោគជ័យជុំវិញការចិញ្ចឹមបសុសត្វនៅរោងចក្រនៅសហរដ្ឋអាមេរិក ការយកព្រុយត្រីឆ្លាមនៅកូស្តារីកា និងក្រៅពីនេះ ការការពារទីរហោស្ថានដែលមានតិចទៅៗរបស់អឺរ៉ុបនៅប៉ូឡូញ កសិកម្មប្រកបដោយចេរភាពនៅគុយបា ការអភិរក្សដែលផ្ដោតទៅលើសិទ្ធិមនុស្សនៅស្វាស៊ីលែនដ៍ និងការអភិរក្សដីរ៉ៃព្រៃនៅកម្ពុជា ។

អ្នកបង្កើតរង្វាន់មនុស្សមាស លោក Richard N. Goldman បានឱ្យដឹងថា "ខ្ញុំត្រូវបានជម្រុញ និងលើកទឹកចិត្តដោយការជម្រុញរបស់បណ្ដាអ្នកដឹកនាំទាំងនេះ" ។ "ការប្ដេជ្ញាចិត្តរបស់ពួកគេ ដែលប្រយុទ្ធប្រឆាំងឱ្យមានអនាគតកាន់តែប្រសើរ បង្ហាញពីការព្យាយាមនៃចលនាបរិស្ថានរបស់ប្រជាជនសាមញ្ញនៅជុំវិញពិភពលោក" ។

ឥឡូវនេះនៅក្នុងសតវត្សទី 21 រង្វាន់ផ្នែកបរិស្ថានមនុស្សមាស (Goldman Environmental Prize) ត្រូវបានផ្ដល់ឱ្យជារៀងរាល់ឆ្នាំទៅឱ្យវីរបុសផ្នែកបរិស្ថានដែលជាប្រជាជនសាមញ្ញ មកពីតំបន់នីមួយៗនៃទ្វីបទាំងប្រាំមួយរបស់ពិភពលោក ហើយគឺជារង្វាន់ដ៏ធំបំផុតនៃរង្វាន់ប្រភេទនេះ ដែលរង្វាន់ជាសាច់ប្រាក់នីមួយៗមានចំនួន $150,000 ។ អ្នកឈ្នះនឹងត្រូវបានផ្ដល់ឱ្យនូវរង្វាន់នៅឯពិធីដែលផ្ដល់ជូនលិខិតអញ្ជើញចូលរួមនៅថ្ងៃ ច័ន្ទ ទី 19 ខែ មេសា ឆ្នាំ 2010 វេលាម៉ោង 5 ល្ងាចនៅ San Francisco Opera House ហើយក៏នឹងត្រូវបានចូលរួមជាកិត្តិយសនៅពិធីតូចមួយទៀតនៅថ្ងៃ ពុធ ទី 21 ខែ មេសា នៅឯ Smithsonian's National Museum of Natural History នៅ Washington, DC ។

**អ្នកឈ្នះក្នុងឆ្នាំនេះមានដូចជា :**

**Thuli Brilliance Makama ស្វាស៊ីលែនដ៍**
Thuli Makama មេធាវីផ្នែកបរិស្ថានដែលផ្ដល់ផលប្រយោជន៍សាធារណៈតែប៉ុណ្ណោះរបស់ប្រទេសស្វាស៊ីលែនដ៍ បានឈ្នះក្ដីដ៏គួរឱ្យចាប់អារម្មណ៍មួយ ក្នុងការបញ្ចូលការតំណាងរបស់អង្គការក្រៅរដ្ឋាភិបាលផ្នែកបរិស្ថាន ក្នុងការធ្វើសេចក្ដីសម្រេចចិត្តអភិរក្ស និងបន្តប្រយុទ្ធប្រឆាំងនឹងការបណ្ដេញចេញដោយបង្ខំ ព្រមទាំងអំពើហិង្សាដែលធ្វើឡើងទៅលើបណ្ដាសហគមន៍ក្រីក្រ ដែលរស់នៅតាមជាយតំបន់អភិរក្ស ។

**Sereivathana Tuy កម្ពុជា**
Sereivathana Tuy បានធ្វើការងារសម្រាលជម្លោះរវាងដំរី-មនុស្សក្នុងប្រទេសកម្ពុជា ដោយណែនាំឱ្យមាននូវដំណោះស្រាយចំណាយទាបប្រកបដោយការច្នៃប្រឌិត ដែលផ្ដល់អំណាចដល់បណ្ដាសហគមន៍ក្នុងមូលដ្ឋាន ចូលរួមសហការក្នុងការអភិរក្សដំរីនៅអាស៊ីដែលរងគ្រោះថ្នាក់ ។

**Małgorzata Górska ប៉ូឡូញ**

Małgorzata Górska បានដឹកនាំប្រយុទ្ធប្រឆាំង Rospuda Valley របស់ប្រទេសប៉ូឡូញ ដែលជាទីរហោស្ថានពិតប្រាកដចុងក្រោយបំផុត មួយក្នុងចំណោមទីរហោស្ថានជាច្រើនរបស់អឺរ៉ុប ពីគម្រោងធ្វើផ្លូវដ៏ចម្រូងចម្រាស់មួយ ដែលនឹងបំផ្លាញដល់ប្រព័ន្ធអេកូឡូស៊ីដ៏ងាយរងគ្រោះ របស់តំបន់។

**Humberto Ríos Labrada គុយបា**

អ្នកវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវជីវចម្រុះ Humberto Ríos Labrada បានជម្រុញឱ្យមានកសិកម្មប្រកបដោយចីរភាព ដោយការធ្វើការងារជាមួយបណ្ដាកសិករ ដើម្បីបង្កើតភាពចម្រុះនៃដំណាំ និងបង្កើតប្រព័ន្ធកសិកម្មដែលមានមុខចូលតិច ដែលកាត់បន្ថយបានច្រើននូវតម្រូវការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជី ដោយលើកទឹកចិត្តឱ្យមានការផ្លាស់ប្ដូរពីការពឹងផ្អែកលើកសិកម្មប្រើប្រាស់ជីគីមីរបស់ប្រទេសគុយបា។

**Lynn Henning សហរដ្ឋអាមេរិក**

កសិករជាលក្ខណៈគ្រួសារម្នាក់នៅតំបន់ជនបទ Michigan ឈ្មោះ Lynn Henning បានបង្ហាញពីការធ្វើការបំពុលដ៏ខ្លាំងរបស់ CAFOs - ជាប្រតិបត្តិការចិញ្ចឹមសត្វលក្ខណៈប្រមូលផ្ដុំ - ដោយទទួលបាននូវចំណាប់អារម្មណ៍ពី EPA របស់សហព័ន្ធ និងជម្រុញឱ្យបណ្ដានិយ័តកររបស់រដ្ឋចេញនូវដីកាជាច្រើន ចំពោះការបំពានទៅលើគុណភាពទឹក។

**Randall Arauz កូស្ដារីកា**

ដោយទាញបាននូវចំណាប់អារម្មណ៍ជាអន្តរជាតិទៅកាន់ឧស្សាហកម្មយកព្រុយត្រីឆ្លាមដោយគ្មានក្ដីមេត្តា និងធ្វើឱ្យមានមហន្តរាយដល់បរិស្ថាន Randall Arauz បានដឹកនាំយុទ្ធនាការបញ្ឈប់ការធ្វើដូចនេះនៅប្រទេសកូស្ដារីកា ដោយធ្វើឱ្យប្រទេសរបស់គាត់ក្លាយជាគំរូជាលក្ខណៈអន្តរជាតិថ្មីមួយសម្រាប់ការការពារត្រីឆ្លាម។

**<u>អំពីរង្វាន់ផ្នែកបរិស្ថានមនុស្សមាស (Goldman Environmental Prize)</u>**

រង្វាន់ផ្នែកបរិស្ថានមនុស្សមាស (Goldman Environmental Prize) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1989 ដោយអ្នកស្នេហាជាតិ និងអ្នកដឹកនាំប្រជាជននៅសាន់ហ្វ្រាន់ស៊ីស្កូលោក Richard N. Goldman និងភរិយាក្រោយរបស់គាត់ Rhoda H. Goldman ។ រង្វាន់នេះត្រូវបានផ្ដល់ឱ្យទៅកាន់មនុស្សចំនួន 139 នាក់មកពី 79 ប្រទេសរួចមកហើយ។

អ្នកឈ្នះរង្វាន់ ត្រូវបានជ្រើសរើសដោយគណៈវិនិច្ឆ័យអន្តរជាតិ ដែលបានពីការតែងតាំងជាសម្ងាត់ ដាក់ជូនដោយបណ្ដាញនៃបណ្ដាអង្គការ និងបុគ្គលផ្នែកបរិស្ថានទូទាំងពិភពលោក។

បណ្ដាអ្នកឈ្នះរង្វាន់កាលពីមុន បានសិតនៅចំកណ្ដាលនៃការប្រកួតប្រជែងផ្នែកបរិស្ថានដែលមានសម្លាចបំផុតរបស់ពិភពលោកមួយចំនួន ដោយរួមទាំងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះពីមហន្តរាយបរិស្ថាននៅ Love Canal and Bhopal ប្រទេសឥណ្ឌា ការដឹកនាំប្រយុទ្ធប្រឆាំងសម្រាប់ត្រីដូហ្វាំង-ធូណា និងការប្រយុទ្ធប្រឆាំងនឹងការខួងយកប្រេងនៅ Arctic National Wildlife Refuge ។

ចាប់តាំងពីទទួល បានរង្វាន់មនុស្សមាស អ្នកឈ្នះរង្វាន់ប្រាំបីនាក់ ត្រូវបានតែងតាំង ឬជាប់ឆ្នោតក្នុងតំណែងថ្នាក់ជាតិនៅប្រទេសរបស់ពួកគេ ដោយរួមមានមួយចំនួនក្លាយជារដ្ឋមន្ត្រីក្រសួងបរិស្ថានផងដែរ។ អ្នកឈ្នះរង្វាន់មនុស្សមាសឆ្នាំ 1991 សម្រាប់ទ្វីបអាហ្វ្រិក Wangari Maathai បានឈ្នះរង្វាន់ណូបែលសន្តិភាពឆ្នាំ 2004 ផងដែរ។

**បណ្ដាអ្នកបោះពុម្ពផ្សាយ :** ព័ត៌មានជីវប្រវត្តិលំអិត និងរូបថតរបស់អ្នកឈ្នះទាំងអស់ អាចទទួលបានតាមសាលសារព័ត៌មានតាមអ៊ិនធ័រណែតរបស់ Goldman Prize តាមការស្នើសុំ។ ក៏អាចទទួលបាននូវវីដេអូ និងសម្លេងផ្សាយដែលមានគុណភាពរបស់បណ្ដាអ្នកឈ្នះនៅក្នុងប្រទេសកំណើតរបស់ពួកគេផងដែរ។ ព័ត៌មានបន្ថែមអំពីរង្វាន់ និងបណ្ដាអ្នកឈ្នះពីមុនមាននៅ www.goldmanprize.org ។